អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ៖ ០០៤/០២/១៩-០៥-២០២០-អ.វ.ត.ក./អ.ជ.ត.ក.(០៤)
Case File/Dossier Nº. 004/02/19-05-2020-ECCC/SC(04)

| | |
|---|---|
| **នៅចំពោះមុខ៖** | **ចៅក្រម គង់ ស្រ៊ឹម, ប្រធាន** |
| | **ចៅក្រម Chandra Nihal JAYASINGHE** |
| | **ចៅក្រម ម៉ុង មុនីចរិយា** |
| | **ចៅក្រម Florence Ndepele Mwachande MUMBA** |
| | **ចៅក្រម យ៉ា ណារិន** |
| | **ចៅក្រម Katrien Gabriël WITTEMAN** |
| | **ចៅក្រម ស៊ិន រិទ្ធ** |
| **កាលបរិច្ឆេទ៖** | **ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤** |
| **ភាសា៖** | **អង់គ្លេស/ខ្មែរ** |
| **ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖** | **សាធារណៈ** |

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 22-Aug-2024, 14:42
CMS/CFO: Sann Rada

---

# ដីកាបង្គាប់ឱ្យធ្វើចំណាត់ថ្នាក់ឡើងវិញឯកសារដែលបានដាក់ក្នុងសំណុំរឿង ០០៤/០២

---

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង
Dale LYSAK

**<u>សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ
Falguni DEBNATH

**<u>សហមេធាវី អោ អាន</u>**

មុំ លុជ្ស
Richard ROGERS
Göran SLUITER

## I. សេចក្តីផ្តើម

១. នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ.") បានស្នើសុំអង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក.) ឱ្យធ្វើចំណាត់ថ្នាក់ឡើងវិញនូវឯកសារដែលស្នើសុំមួយចំនួន ក្នុងសំណុំរឿង ០០៤/០២ ពីប្រភេទសម្ងាត់ឬសម្ងាត់បំផុតទៅជាប្រភេទសាធារណៈវិញ[1] "បន្ទាប់ពីមានការអនុវត្តលើការកោសលុបចាំបាច់ណាមួយលើព័ត៌មានដែលត្រូវការពារ"[2]។ ស.ព.អ. ក៏បានជំរុញឱ្យ អ.ជ.ត.ក. "បង្កើតគោលនយោបាយមួយដើម្បីគ្រប់គ្រងលើលទ្ធភាពចូលពិនិត្យឯកសារទាំងអស់ដែលនៅរក្សាការសម្ងាត់ ឬសម្ងាត់បំផុត បន្ទាប់ពីមានដំណោះស្រាយរបស់អង្គជំនុំជម្រះតុលាការកំពូលលើសំណើនេះ ឬសំណើពាក់ព័ន្ធ"[3]។

២. នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៣ អ.ជ.ត.ក. បានអនុម័តសេចក្តីណែនាំទូទៅសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញក្នុងសំណុំរឿង ០០៤/០២[4]។ អ.ជ.ត.ក. បានទទួលបញ្ជីឯកសារទាំងអស់ដែលបានដាក់ក្នុងសំណុំរឿង ០០៤/០២ ពីអង្គភាពបណ្ណសារ ក្នុងទម្រង់ជាសៀវភៅបញ្ជី (spreadsheet)។ សៀវភៅបញ្ជីរៀបរាប់ឯកសារចំនួន ៣៥.៤៦១ ក្នុងចំណោមនោះឯកសារសាធារណៈមានចំនួន ១.៩៨៦ ឯកសារសម្ងាត់មានចំនួន ៣៣.៤២២ និងឯកសារសម្ងាត់បំផុតមានចំនួន ៥៣។

## II. ពិភាក្សា

៣. អនុលោមតាមមាត្រា ១២ នៃសេចក្តីណែនាំអនុវត្តស្តីអំពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង (វិសោធនកម្មលើកទី២) ("សេចក្តីណែនាំអនុវត្ត") អ.ជ.ត.ក. ក្នុងនាមជាការិយាល័យតុលាការចុងក្រោយដែលត្រូវបានប្តឹងអំពីសំណុំរឿង ០០៤/០២ បានបញ្ចប់ការពិនិត្យឡើងវិញនៃឯកសារក្នុងសំណុំរឿងនេះ ក្នុងគោលបំណងធ្វើចំណាត់ថ្នាក់ឡើងវិញស្របតាមសេចក្តីណែនាំ។

---

[1] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំធ្វើចំណាត់ថ្នាក់ឡើងវិញចំពោះឯកសារនៅក្នុងសំណុំរឿង ០០៤/២ ឯកសារ E004/2/7 ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ("សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញ")។

[2] សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញ កថាខណ្ឌ ១០៨។

[3] សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញ កថាខណ្ឌ ៧។ *សូមមើលផងដែរ* សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញ កថាខណ្ឌ ៣០។

[4] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញក្នុងសំណុំរឿង ០០៤/២ (E004/2/7) ឯកសារ E004/2/7/1 ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៣ ("សេចក្តីណែនាំ")។

៤. អ.ជ.ត.ក. បានបញ្ជាក់ការកំណត់របស់ខ្លួនថាតើត្រូវដកចំណាត់ថ្នាក់សម្ងាត់ចេញ ធ្វើចំណាត់ថ្នាក់ឡើងវិញ ឬ ត្រូវកោសលុបដែរឬយ៉ាងណា ចំពោះឯកសារដែលបានដាក់ក្នុងសំណុំរឿង ០០៤/០២ ដោយបង្គាប់ឱ្យអនុលោមតាមសៀវភៅបញ្ជីភ្ជាប់មកជាមួយដីកាបង្គាប់បច្ចុប្បន្ននេះ (“ឧបសម្ព័ន្ធ”)[5]។ សេចក្ដីណែនាំរបស់ អ.ជ.ត.ក. នោះ មានចែងដូចខាងក្រោម៖

៥. “**គ្មានវិធានការណ៍**” បញ្ជាក់ថាឯកសារមិនត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញទេ ពោលគឺ ចំណាត់ថ្នាក់បច្ចុប្បន្នរបស់ឯកសារគប្បីរក្សាទុកនៅដដែល។

៦. “**ដកចំណាត់ថ្នាក់សម្ងាត់ចេញ**” បញ្ជាក់ថា ឯកសារគប្បី ត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ ជា “សាធារណៈ” ដោយគ្មានការកោសលុបណាមួយឡើយ។

៧. “**ធ្វើចំណាត់ថ្នាក់ឡើងវិញ**” បញ្ជាក់ថាឯកសារគប្បីធ្វើចំណាក់ថ្នាក់ឡើងវិញជា “សម្ងាត់” ឬ “សម្ងាត់បំផុត” ដូចបានបញ្ជាក់ក្នុង ឧបសម្ព័ន្ធ។

៨. “**កោសលុប**” បញ្ជាក់ថា ឯកសារ គប្បីត្រូវកោសលុប ផ្នែកព័ត៌មានរសើប ឬ ព័ត៌មានកំណត់អត្តសញ្ញាណ (ដូចជាឈ្មោះរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឬសាក្សី និងសមាជិកគ្រួសាររបស់គាត់ ព្រមទាំង ព័ត៌មានទំនាក់ទំនងលម្អិត ដូចជាលេខទូរសព្ទ ឬអាសយដ្ឋានស្នាក់នៅ) ស្របតាមសេចក្ដីណែនាំ និងភាពជាក់លាក់ណាមួយបន្ថែមទៀតដែលអាចមានចែងនៅក្នុង ឧបសម្ព័ន្ធ។

៩. អ.ជ.ត.ក. សង្កត់ធ្ងន់ថា ការកោសលុប ត្រូវមានសង្គតិភាពចំពោះគ្រប់ភាសានៃឯកសារមួយ។ ដូចនេះ អង្គភាពបណ្ណសារ ត្រូវកំណត់វិធីសាស្ត្រមួយដែលធានាបានសង្គតិភាពនេះ។

១០. ក្រោយពីការចេញ និងការអនុវត្តដីកាបង្គាប់បច្ចុប្បន្ននេះ អង្គភាពបណ្ណសារត្រូវបង្វែរឯកសារដែលបានដកចំណាត់ថ្នាក់សម្ងាត់ និងឯកសារដែលបានកោសលុបត្រឡប់មក អ.ជ.ត.ក. វិញ ដើម្បីធ្វើការពិនិត្យជាលើកចុងក្រោយ និងអនុម័តយល់ព្រម មុនពេលជូនដំណឹងអំពីឯកសារទាំងអស់នេះ[6]។

---

[5] ឧបសម្ព័ន្ធនេះ ត្រូវបានដាក់ដោយឡែកនិងដាក់ចំណាត់ថ្នាក់ “សម្ងាត់បំផុត ”។

[6] *សូមមើល* សំណុំរឿង ០០២ សេចក្ដីសម្រេចស្ដីពីសេចក្ដីណែនាំសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញក្នុងសំណុំរឿង ០០២ ឯកសារ F71/1/1/8 ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ កថាខណ្ឌ ៥៩ *ដូចដែលបានអនុម័តដោយ* សេចក្ដីណែនាំ ទំព័រ ៣។ *សូមមើលផងដែរ* សេចក្ដីណែនាំអនុវត្ត មាត្រា ៩.២.គ។

១១. អង្គភាពបណ្ណសារក៏ត្រូវបោះពុម្ពផ្សាយនូវបញ្ជីមួយមានរៀបរាប់ឯកសារទាំងអស់ ដែលត្រូវបានធ្វើឱ្យទៅជាសាធារណៈ ដែលជាលទ្ធផលនៃការដកចំណាត់ថ្នាក់ឯកសារ និងការកោសលុប បន្ទាប់ពីបានដាក់ និងជូនដំណឹងទៅកាន់ភាគីទាំងអស់។

១២. សេចក្ដីសម្រេច ទាក់ទងនឹងសំណើសុំឱ្យ អ.ជ.ត.ក. បង្កើតសេចក្ដីណែនាំ ស្ដីពីការចូលប្រើប្រាស់ឯកសារ បន្ទាប់ពីដំណោះស្រាយនេះនិងសំណើដែលនៅសេសសល់សុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ នឹងចេញក្នុងពេលកំណត់សមស្រប។

## III. ផ្នែកសម្រេចសេចក្ដី

១៣. **ផ្អែកលើមូលហេតុដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះតុលាការកំពូល៖**

**បង្គាប់** ឱ្យអង្គភាពបណ្ណសារធ្វើការដកចំណាត់ថ្នាក់ឯកសារ ធ្វើចំណាត់ថ្នាក់ឡើងវិញ ឬកោសលុបឯកសារក្នុងសំណុំរឿង ០០៤/០២ ដូចបានបញ្ជាក់ក្នុង ឧបសម្ព័ន្ធ និងស្របតាមសេចក្ដីណែនាំ ក៏ដូចជាបញ្ជាក់ខាងលើ។

ភ្នំពេញ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**